CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

# BI-WEEKLY BULLETIN

លេខទី៥០ ឆ្នាំ២០២១ (ថ្ងៃទី១៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១)

CRF2021/050 (14 to 27 June 2021)

## ព័ត៌មានអំពីវិស័យស្រូវអង្ករ *(Rice News Briefing)*

### ក្នុងប្រទេស (In Cambodia)



យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចរយៈពេល ៣ឆ្នាំរបស់កម្ពុជានឹងផ្តោតលើការនាំចេញ

**Cambodia's economic diplomacy strategy 2021-2023 focusing on rice export**

*Post Khmer: 15 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

ក្រសួងប្រកាសថា GI ទឹកឃ្មុំ និងអំបុក ទទួលបានការទទួលស្គាល់ជាផ្លូវការ ក្នុងឆ្នាំ២០២១

**GI honey, rice flakes' official recognition in 2021: ministry**

*Phnom Penh Post: 24 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





ប្រទេសកម្ពុជា និងអង់គ្លេសពិចារណាលើការសម្របសម្រួលកិច្ចសហការ លើអនុស្សរណៈពាណិជ្ជកម្ម

**Cambodia, UK mull trade facilitation MoU**

*Phnom Penh Post: 24 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

## ហ្វីលីពីន ( Philippines )

### តម្លៃអង្ករនៅតែកើនឡើង ទោះបីជាផលិតកម្មនិងការនាំចូលកើនឡើងក៏ដោយ

### Rice prices still rising despite higher production, imports

*Inquirer net: June 14, 2021*    ចុចទីនេះ ដើម្បីអាន ( Click here to read)






## កេនយ៉ា ( Kenya )

### កេនយ៉ា នឹងចាប់ផ្តើមផលិតកម្មបែបពាណិជ្ជកម្មនៃអង្ករHybrid និងកាត់បន្ថយការនាំចូល

### Kenya to start commercial production of hybrid rice, cut imports

*Xinhua Net: June 14, 2021*    ចុចទីនេះ ដើម្បីអាន ( Click here to read)

## ប៉ាគីស្ថាន ( Pakistan )

### ពិព័ណ៌អង្ករតាមអនឡាញឆ្នាំ២០២១ របស់សមាគមអ្នកនាំចេញអង្ករប៉ាគីស្ថាន ទទួលបានការឆ្លើយតបយ៉ាងអស្ចារ្យ

### REAP’s ‘Virtual Rice Expo 2021’ gets overwhelming response

*Business Recorder: June 17, 2021*    ចុចទីនេះ ដើម្បីអាន ( Click here to read)





## វៀតណាម ( Vietnam )

### អ្នកលួចបន្លំក្នុងប្រភពដើមអាចធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអង្កររបស់ប្រទេសវៀតណាម

### Origin fraud may erode Vietnamese rice’s prestige: insiders

*Vietnam Plus: June 18, 2021*    ចុចទីនេះ ដើម្បីអាន ( Click here to read)

### ពូជស្រូវមានគុណភាពត្រូវការបរិមាណតិចជាងនេះក្នុងមួយហិកតា

### Quality rice seed seen requiring smaller quantities per hectare

*Business World: June 18, 2021*    ចុចទីនេះ ដើម្បីអាន ( Click here to read)





បង់ក្លាដេស ( Bangladesh )

### បង់ក្លាដេសនៅតែបន្តនាំចូលអង្ករពីប្រទេសមីយ៉ាន់ម៉ា
### Bangladesh continues to import rice from Myanmar

*Dhaka Tribune: June 24, 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

ហ្វីលីពីន ( Philippine )

### ច្បាប់ពន្ធគយទទួលបានទស្សនៈចម្រុះ
### Rice tariffication law gets mixed views

*The Manila Times: June 24, 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



សហរដ្ឋអាមេរិក ( USA )

### អ្នកស្រាវជ្រាវបំបែកភាពស្មុគស្មាញនៃអាថ៌កំបាំងឫសគល់ស្រូវ
### Researchers crack twirling rice root mystery

*The Western Producer: June 24, 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

ថៃ ( Thailand )

### ប្រទេស ចិនបញ្ជាក់ពីការទិញអង្ករចំនួន ២ ម៉ឺនតោន
### China confirms purchase of 20,000 tonnes of rice

*The Bangkok Post: June 28, 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



វៀតណាម ( Vietnam )

### ការនាំចូលអង្ករឥណ្ឌាកើនឡើង ហើយក្រសួងបង្កើតក្រុមអធិការកិច្ច
### Imports of Indian rice surge, Ministry sets up inspection team

*Vietnam Net: June 28, 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



# កិច្ចសម្ភាសន៍ អំពីស្រូវអង្ករកម្ពុជា សម្រាប់វីដេអូឯកសាររបស់ទូរទស្សន៍អឺរ៉ុប

## CRF to feature in the European Culture TV program on Cambodian Rice

កាលពីសប្តាហ៍មុន ត្រូវនឹងថ្ងៃសុក្រ ទី១៨ ខែមិថុនា ឆ្នាំ២០២១ **ឧកញ៉ា សុខ សារ៉េន ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា** បានផ្តល់កិច្ចសម្ភាសន៍ដោយផ្ទាល់នៅវាលស្រែ ក្បែរតំបន់អាងកំពីងកំពួយ ខេត្តបាត់ដំបង ជាមួយនឹងកម្មវិធីឈ្មោះ INVITATION AU VOYAGE ដែលជាកម្មវិធីផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍របស់ អឺ រ៉ុប Arte ជាភាសាបារាំង-អាល្លឺមង់។

កម្មវិធីផ្សាយនេះ គឺជាកម្មវិធីដំណើរកម្សាន្តទាក់ទងនឹងវប្បធម៌ ហើយក្នុងនោះ ប្រទេសកម្ពុជាត្រូវបានទទួលនូវការចាប់អារម្មណ៍ខ្ពស់ ទៅលើវប្បធម៌ប្រវត្តិសាស្រ្ត ការរីកចំរើនផ្នែកកសិកម្មជពិសេសលើការផលិតស្រូវអង្ករ ក្រអូបនេះតែម្តង។ វីដេអូឯកសារនេះនឹងបង្ហាញអំពី ខេត្តបាត់ដំបង ដោយផ្តោតយកទិដ្ឋភាព ទេសភាព រចនាបទសំណង់ក្នុងខេត្ត រមណីយដ្ឋានសំខាន់ និងការរីកចម្រើននៃវិស័យស្រូវអង្ករកម្ពុជា ដែលខេត្តបាត់ដំបង ជាជង្រុកស្រូវក្រអូបដ៏ធំជាងគេនៅកម្ពុជា។

ឧកញ៉ា ប្រធានសហព័ន្ធ បានបង្ហាញអំពីវឌ្ឍនៈភាពនៃវិស័យស្រូវអង្ករកម្ពុជា ធ្លាប់ជាប្រទេសដែលខ្វះខាតស្បៀងអាហារ មកជាប្រទេសដែលផលិត ហើយមានអតិរេក លើការប្រើប្រាស់ក្នុងស្រុក ហើយបាននិងកំពុងនាំចេញទៅកាន់ទីផ្សារអន្តរជាតិជាង៦០ប្រទេសផងដែរ។

ឧកញ៉ាប្រធានសហព័ន្ធក៏បានលើកអំពីភាពប្រណិត និងគុណតម្លៃនៃអង្ករក្រអូបរបស់កម្ពុជា ដែលធ្លាប់បានទទួលបាននូវពានរង្វាន់អង្ករល្អបំផុតលើពិភពលោកចំនួន៤ឆ្នាំ ជូនដល់សាធារណៈជន និងអំពាវនាវឱ្យជួយទិញអង្ករកម្ពុជាអោយបានកាន់តែច្រើនថែមទៀត ហើយក៏បានថ្លែងអំណរគុណចំពោះការចាប់អារម្មណ៍របស់សារព័ត៌មានបរទេសមកលើកម្ពុជា តាមរយៈវីដេអូឯកសារនេះ ដែលនឹងនាំឱ្យពិភពលោកកាន់តែស្គាល់អំពីកិត្តិនាមរបស់កម្ពុជា ជាពិសេសគឺលើស្រូវអង្ករកម្ពុជា។ កម្រងអត្ថបទ នៃបទយកការណ៍នេះនឹង ចាក់ផ្សាយ នៅក្នុងរដូវផ្ការីកខាងមុខនៅក្នុងប្រទេសបារាំងនិងប្រទេសអាឡឺម៉ង





Click here for English article:
[CRF to feature in the European Culture TV program on Cambodian Rice]

# ព្រឹត្តិការណ៍/សកម្មភាព
Event/ Activity




## ពិធីចុះហត្ថលេខាលើការគាំទ្រនូវការបង្កើតសាខាថ្នាក់ជាតិវេទិកាស្រូវអង្ករប្រកបដោយនិរន្តរភាព ( SRP National Chapter ) ក្នុងប្រទេសកម្ពុជា

## Signing Ceremony to support the development of Sustainable Rice Platform National Chapter in Cambodia

នាព្រឹកថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ **ឧកញ៉ា សុង សារ៉ន ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា** បានចូលរួមថ្លែងសុន្ទរកថា ក្នុងឱកាសពិធីចុះហត្ថលេខាលើកិច្ចសន្យា ស្ដីអំពីការបង្កើតសាខាថ្នាក់ជាតិរបស់វេទិកាស្រូវអង្ករប្រកបដោយនិរន្តរភាព នៅក្នុងប្រទេសកម្ពុជា តាមរយៈអនឡាញ ដែលមានការចូលរួមជាអធិបតីភាពពីសំណាក់ **ឯកឧត្ដមបណ្ឌិត ងិន ឆាយ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម។

ពិធីចុះហត្ថលេខានាថ្ងៃនេះ គឺជាការកើតឡើងតាមរយៈកិច្ចពិភាក្សា និងការរៀបចំនានាជាច្រើនរបស់ក្រុមការងារ ដែលចូលរួមពីអគ្គនាយកដ្ឋានកសិកម្ម លេខាធិការដ្ឋានសហព័ន្ធស្រូវអង្ករកម្ពុជា អង្គការ Swiss Contact អង្គការ WCS, អង្គការ CIRAD និងអង្គការផ្សេងមួយចំនួនទៀត។

នៅក្នុងសុន្ទរកថាតំណាងឱ្យសហព័ន្ធស្រូវអង្ករកម្ពុជា ឧកញ៉ា សុង សារ៉ន បានសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងនូវវឌ្ឍនភាពថ្ងៃនេះ ដែលជាកម្មវិធីមួយរួមគ្នារវាងស្ថាប័នសាធារណៈ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងគោលបំណងផ្ដល់អត្ថ-ប្រយោជន៍ដល់គ្រប់ភាគី ជាពិសេស គឺជួយដល់កសិករ និងអ្នកប្រើប្រាស់ ( Public Development Partner Private Sector Partnership for Producers )។ លោកបានបង្ហាញក្ដីសង្ឃឹមជឿជាក់ថា ៖ "តាមរយៈកិច្ចព្រមព្រៀងថ្ងៃនេះ វានឹងជួយជំរុញដល់វិស័យស្រូវអង្ករកម្ពុជាបន្ថែមទៀត ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការធ្វើពិពិធកម្មទីផ្សារ និងពិពិធកម្មផលិតកម្ម តាមប្រភេទពូជ និងក្រុមប្រភេទស្រូវ-អង្ករ និងជាពិសេសគឺផ្ដល់នូវទីផ្សារបន្ថែមដល់កសិករខ្នាតតូចនៅកម្ពុជា ក្នុងការបង្កើនតម្លៃស្រូវរបស់ខ្លួននិងគិតគូរដល់បរិស្ថាន។

ក្នុងអំឡុងពេលនៃការចុះហត្ថលេខានេះដែរ ឯកឧត្ដមបណ្ឌិត ងិន ឆាយ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះដៃគូទាំងអស់ រួមមានវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដែលបានខិតខំធ្វើការរួមគ្នាជាមួយអគ្គនាយកដ្ឋានកសិកម្ម ក្នុងការបង្កើតនិងលើកកម្ពស់នូវ SPR national Chapter។ ឯកឧត្ដមមានប្រសាសន៍ថា "SPR National Chapter នេះ ពិតជាត្រូវនឹងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រវិស័យកសិកម្ម ២០១៩-២០២៣ ស្ដីពីការលើកកម្ពស់ផលិតភាពកសិកម្ម ពិពិធកម្ម ការប្រកួតប្រជែង និងពាណិជ្ជកម្ម ហើយស្ដង់ដាររបស់វា គួរតែត្រូវបានអនុវត្តឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅគ្រប់ប្រព័ន្ធអេកូឡូស៊ីផលិតកម្មស្រូវ នៅក្នុងប្រទេសកម្ពុជា សម្រាប់ការកែលម្អផលិតភាពស្រូវ ធានាសុវត្ថិភាពម្ហូបអាហារ និងបង្កើនប្រាក់ចំណេញ ក្នុងលក្ខណៈប្រកបដោយនិរន្តរភាពសម្រាប់ផ្គត់ផ្គង់ទីផ្សារប្រកួតប្រជែង។

លោកបណ្ឌិត Wyn Ellis អគ្គនាយកប្រតិបត្តិ SRP បានមាន






ប្រសាសន៍អបអរសាទរដល់កម្មវិធីចុះហត្ថលេខានាថ្ងៃនេះថា ពិតជាការបោះជំហានមួយដ៏សំខាន់របស់កម្ពុជា ឆ្ពោះទៅរកការកសាងនូវតួនាទីជាតួអង្គមួយ ដ៏សំខាន់នៅក្នុងស្រូវអង្ករប្រកបដោយនិរន្តរភាព ដែលក្នុងនោះ ជាក់ស្តែង ពានរង្វាន់អង្ករល្អបំផុត ផ្ការំដួលរបស់កម្ពុជា សមស្របឥតខ្ចោះ នឹងតម្រូវរបស់សកលលោក ជាមួយនឹងអង្ករបញ្ជាក់គុណភាព SRP ដែលមានវត្តមាន នៅទីផ្សារអឺរ៉ុបកន្លងមករួចទៅហើយ ហើយការប្តេជ្ញាចិត្តរបស់ភាគីទាំងអស់ចំពោះ SPR National Chapter នៅកម្ពុជា នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់អត្ថប្រយោជន៍នៃអង្ករប្រកបដោយនិរន្តរភាពទៅដល់កសិករ អាជីវកម្ម និងបរិស្ថាន។

គួរបញ្ជាក់ផងដែរថា កម្ពុជាបានចូលរួមនៅក្នុងវេទិកាស្រូវអង្ករប្រកបដោយនិរន្តរភាព (SRP) នេះ តាំងពីឆ្នាំ២០១៥ នៅក្នុងសន្និបាតថ្នាក់សកលរបស់ SRP ដែលមានឯកឧត្តមបណ្ឌិត ងិន ឆាយ បានចូលរួម ក៏ដូចជាមាននូវការចូលរួមពី អ្នកនាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ អង្គការស្ថាប័នអភិវឌ្ឍនានា ផងដែរ។ បន្ទាប់មក នៅឆ្នាំ ២០១៦ SPR នេះ ត្រូវបានយកមកអនុវត្តនៅកម្ពុជា ដោយមានការសម្របសម្រួលពីភាគីពាក់ព័ន្ធនានា ដែលក្នុងនោះ មាននូវសមាជិកសហ ព័ន្ធស្រូវអង្ករកម្ពុជា បានយកគំរូស្តង់ដារនេះ មកអនុវត្តនៅក្នុងការសហការជាមួយនឹងសហ គ ម ន៍ កសិកម្ម តាមរយៈកិច្ចសន្យាកសិកម្ម ដែលជាជំហានសាកល្បង បានធ្វើនៅក្នុងខេត្តកំពង់ធំ និង បាត់ដំបង។ ជាជំហានបន្ទាប់ នៅក្នុងឆ្នាំ២០១៩ មហាសន្និបាតថ្នាក់សកលត្រូវបានរៀបចំឡើង នៅខេត្តសៀមរាប ដោយមានអធិបតីភាព ចូលរួមបើក មហា សន្និបាតនេះ ពីសំណាក់ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ហើយដែលនៅក្នុងកិច្ចប្រជុំ របស់មហាសន្និបាតនោះ ក៏មាននូវការព្រមព្រៀងបង្កើត នូវសាខា ថ្នាក់ជាតិ របស់វេទិកា ស្រូវអង្ករប្រកបដោយនិរន្តរភាព នៅកម្ពុជា នេះ។

Click here for English article:
Signing Ceremony to support the development of Sustainable Rice Platform National Chapter in Cambodia









# តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
# (Paddy price & FOB Price)

## តម្លៃស្រូវ នៅវាលស្រែ
### ដែលកំពុងប្រមូលផល តាមបណ្តាខេត្តមួយចំនួន

ថ្ងៃចន្ទ ទី២៨ ខែមិថុនា ឆ្នាំ២០២១

គិតជារៀល/គីឡូក្រាម

| ខេត្ត | ស្រុក | សែនក្រអូប | អូអឹម ៥៤៥១ | អ៊ីរ៉ែរ ៨៥ | ផ្សេងៗ |
|---|---|---|---|---|---|
| កំពង់ធំ | ស្ទឹងសែន | | 830-850 | | |
| | ស្ទោង | | 820-840 | | |
| | សន្ទុក | | 820-840 | | |
| បាត់ដំបង | បាណន់ | 990-1050 | 890-910 | 870-900 | 930-950 |
| កំពង់ឆ្នាំង | កំពង់ត្រឡាច | | 860-880 | 860-880 | |
| | កំពង់លែង | | 820-840 | | |
| ព្រៃវែង | ពារាំង | | 830-850 | | |
| | ស្វាយអន្ទរ | | 830-850 | | |
| | កំចាយមារ | | 820-840 | | |
| | កំពង់ត្របែក | | 820-840 | | |
| ស្វាយរៀង | រមាសហែក | | | 800-830 | |
| តាកែវ | អង្គរបុរី | | 840-860 | | |

**ប្រភពទិន្នន័យ**

- សហគមន៍កសិកម្មនៅតាមបណ្តាខេត្ត
  ១. ក្រុងស្ទឹងសែន ខេត្តកំពង់ធំ (078 576321)
  ២. ស្រុកបាណន់ ខេត្តបាត់ដំបង (012 824 665)
  ៣. ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង (089 509 232)
  ៤. ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (097 907 0328)
  ៥. ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង (088 873 3377)
- Agribee Cambodia PLC (096 77 00 111)


**សហព័ន្ធស្រូវអង្ករកម្ពុជា** (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀងដោយ (Prepared by)**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

+855 23 559 8999
info@crf.org.kh
www.crf.org.kh
www.facebook.com/cambodiaricefederation
twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation